ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុនGlobal Bridge Co,Ltd

ប្រទេសជប៉ុន

សូមគោរពជូន

លោកប្រធានមន្ទីរអប់រំ

យុវជន និងកីឡាខេត្តសៀមរាប

កម្មវត្ថុ៖ សំណើរសុំចុះផ្សព្វផ្សាយកម្មវិធីអាហារូបករណ៍សម្រាប់សិក្សានៅសកលវិទ្យាល័យ ដល់សិស្សានុសិស្សថ្នាក់ទី១២នៅតាម វិទ្យាល័យក្នុងខេត្តសៀមរាប ។

យោង៖ កិច្ចសហប្រតិបត្តិការ រវាងក្រុមហ៊ុនGlobal Bridge Co,Ltd ប្រទេសជប៉ុន និងមន្ទីរអប់រំយុវជន និងកីឡាខេត្តសៀមរាប។

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំមានកិត្តិយស សូមគោរពជម្រាបជូនលោកប្រធានមេត្តាជ្រាបថា កន្លងមកក្រុមហ៊ុនយើងខ្ញុំបានជួយសាងសង់អគារសិក្សាសម្រាប់សិស្សថ្នាក់មត្តេយ្យ១ខ្នង ៣បន្ទប់ នៅក្នុងសាលាបឋមសិក្សាសសរស្តម្ភ និងបានផ្តល់អាហារូបករណ៍ដល់សិស្សថ្នាក់ទី១២នៅវិទ្យាល័យសសរស្តម្ភចំនួន ៤នាក់ សម្រាប់ពីរជំនាន់(មួយជំនាន់២នាក់)រួចមកហើយ ។ដោយក្រុមហ៊ុនយើងខ្ញុំមានបំណង ចង់ចូលរួមកសាងធនធានមនុស្សក្នុងប្រទេសកម្ពុជា ដោយឡែកក្នុងខេត្តសៀមរាប ទើបសុំការអនុញ្ញាតពីលោកប្រធាន ចុះផ្សព្វផ្សាយឲ្យបាន ទូលំទូលាយដល់សិស្សានុសិស្សថ្នាក់ទី១២ទូទាំងខេត្តសៀមរាប ដើម្បីឲ្យពួកគាត់មានឱកាស ដាក់ពាក្យប្រឡងប្រណាំងយក អាហារូបករណ៍ពីក្រុមហ៊ុនGlobal Bridge Co,Ltd សម្រាប់បន្តការសិក្សានៅសកលវិទ្យាល័យ ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូមលោកប្រធានមេត្តាពិនិត្យលទ្ធភាព ឲ្យក្រុមការងារយើងខ្ញុំបានចុះផ្សព្វផ្សាយនៅតាមវិទ្យាល័យក្នុងខេត្តសៀមរាប ដោយក្តីអនុគ្រោះ។

សូមលោកប្រធានទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ… ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

សៀមរាបថ្ងៃទី.20...ខែ.កញ្ញា.ឆ្នាំ២០១៩

ប្រធានក្រុមហ៊ុនGlobal Bridge Co,Ltd

貞松 成

Joe. Sadamatsu.

លេខ ១៦៧........**អយក.មបន**

បានឃើញ និងបញ្ជូនមកលោក លោកស្រី នាយក នាយិកា វិទ្យាល័យទាំងអស់ទូទាំងខេត្ត "ដើម្បីសម្របសម្រួលសហការឱ្យបានល្អប្រសើរ"

ថ្ងៃ… ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

សៀមរាប ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០១៩

ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត

សយ ធិក្សាចឿ